ប៉ះពាល់ដល់ជីវភាព ឬមួយក៏ផលប្រយោជន៍របស់បងប្អូនរស់នៅតាមមូលដ្ឋាន ដូចច្នេះដំណើរការរបស់ក្រុមហ៊ុនកន្លងមកគឺមិនមានបញ្ហាអ្វីទាល់តែសោះ។ ដើម្បីបញ្ជាក់បន្ថែមពីលើអ្វីដែលខ្ញុំបានបកស្រាយ នេះគឺជាក់ស្តែងក្រុមហ៊ុន **បា វ៉ា** យើងឃើញថាចំនួនផ្ទៃដីដែលយើងបានចុះទៅសិក្សា គឺមានប្រមាណជា ៩២០០ ហិកតានេះភាគច្រើន គឺក្រុមហ៊ុនបានដាំដុះកៅស៊ូស្ទើតែពេញអសលទៅហើយ ហើយ ចំពោះកូនកៅស៊ូនៅទីនោះគឺវាមានលក្ខណៈប្រហាក់ប្រហែលគ្នា (រូបភាពនៅក្នុងរបាយការណ៍) រូបភាពនេះអញ្ចឹងគឺស្ថានភាពព្រៃដែលមាននៅក្នុងក្រុមហ៊ុនដែលយើងមើល ទៅជាព្រៃស្រោងដែលមានភាពរេចរឹលគឺមិនឃើញមានមេឈើពូជអ្វីនៅសេសសល់នោះទេ ស្ថានភាពព្រៃនេះអាចឱ្យយើងសន្និដ្ឋានបានថា ព្រៃនេះរងនូវការធ្វើអាជីវកម្មនឹងមានការដកហូតយកឈើដែលមានតំលៃសេដ្ឋកិច្ចយ៉ាងតិច៥-៦ដងហើយដែរ អញ្ចឹងឈើគឺអស់ គឺនៅសល់តែកូនឈើដុះនៅសាក្រោយតែប៉ុណ្ណោះ។ ចំពោះក្រុមហ៊ុន **ឥាន់ បឿន** កៅស៊ូដែលគាត់បានធ្វើការដាំដុះនៅឆាំទី១ ក្រុមហ៊ុនគ្រោងនឹងធ្វើការជៀជ័រនៅឆ្នាំ២០១៣ខាងមុខនេះ។ ដោយសារតែព្រៃឈើទាំងអស់នេះ គឺក្រុមហ៊ុនបានធ្វើការឈូសឆាយអស់ហើយ ម្យ៉ាងវិញទៀត ជាទូទៅយើងគិតថារាល់គំរោងនៃការអភិវឌ្ឍន៍នីមួយ១ វាតែងតែមានផលប៉ះពាល់ទាំងបរិស្ថាននិងសង្គម ដែលផលប៉ះពាល់ទាំងអស់នេះ គឺយើងមានសរសេរល់អិតនៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននេះតែម្តង តែបើសិនជាយើង លើកយករបាយការណ៍នេះយកនិយាយទាំងស្រុងតែម្តងប្រហែលជាពេលវេលាយើងមិនអំណោយផលទេ ម្យ៉ាងដោយសារព្រៃនៅតំបន់នេះ គឺយើងធ្វើការឈូសឆាយអស់ទៅហើយ ជាទូទៅវិធានការនៃការកាត់បន្ថយការ ហូរច្រោះអីយ៉ាងម៉េចនោះ គឺមានសរសេរនៅក្នុងរបាយការណ៍អស់ហើយ ប៉ុន្តែអ្វីដែលពាក់ព័ន្ធទៅនឹងក្រុមហ៊ុនទាំង បីនេះដែលបានអនុវត្តន៍ការងារកន្លងមកគឺគាត់មិនទាន់យល់ស៊ីជំរៅអំពីបញ្ហាច្បាប់ ជាពិសេសព្រៃរក្សាទុកនៅតាមតំបន់ដងអូរនេះ អញ្ចឹងក៏មានប្រជាជននៅខាងក្រៅគាត់រានចូលទៅធ្វើការកាន់កាប់ដីនោះទៅ ជាក់ស្តែងនៅពេលដែលឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ដែលឯកឧត្តមអញ្ជើញចូលរួម នៅក្នុងពិធីសម្ពោធបើកអោយប្រើប្រាស់សាលារៀន និង ប៉ុស្តិ៍សុខភាពនៅក្នុងតំបន់នោះ បានពិនិត្យឃើញថា ព្រៃនៅតាមដងអូរដែលត្រូវអោយរក្សាទុកតាមបទដ្ឋានច្បាប់នោះ ក្រុមហ៊ុនមិនបានប្រើប្រាស់ទេ ប៉ុន្តែគាត់មិនយល់អំពីកត្តព្វកិច្ចរបស់គាត់ក្នុងការគ្រប់គ្រងថែរក្សាព្រៃអភិរក្សនោះ ប្រជាជនក៏ចូលទៅធ្វើការកាប់រានស្ទើតែអស់ទាំងស្រុង ដូច្នេះដល់ពេលអញ្ចឹងក្រុមហ៊ុនត្រូវបានទទួលការស្តីបន្ទោសពីគណៈប្រតិភូ ក្នុងពេលនេះមានការអមដំណើរផងដែរ ដោយឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **ច័ន្ទ សារុន** និង ឯកឧត្តម **វ៉ាន់ ផាណ្ណា** ក្នុងនោះផងដែរក៏មាននាយករងរដ្ឋបាលព្រៃឈើមកពីភ្នំពេញគឺ លោក **អ៊ុង សំអាត** ក្នុងការចូលរួមធ្វើការទិតៀន ពេលដែលក្រុមគណៈប្រតិភូបានត្រឡប់ទៅភ្នំពេញវិញនោះក៏មានការកោះហៅក្នុងការប្រជុំពិភាក្សាលើបញ្ហានេះ។ ប៉ុន្តែរឿងរ៉ាវទាំងអស់នេះ គឺយើងមិនដឹងថាចុងក្រោយទៅអង្គភាពជំនាញនេះត្រូវអោយស្តារឬមួយក៏យ៉ាងដូចម្តេចនោះទេ ខ្ញុំគិតថាវាស្ថិតនៅក្រៅវង្វង់សមត្ថកិច្ចដែល **កុង ស៊ុលតង់** ឯករាជ្យមួយធ្វើការវះកាត់លើបញ្ហានេះ ប៉ុន្តែបើសិនជានៅក្នុងច្បាប់បរិស្ថាន

គាត់ប្រហែលជាអាចទទួលការផាកពិន័យ ឬមួយក៏ទាមទារអោយក្រុមហ៊ុនធ្វើការដាំស្តារព្រៃនេះឡើងវិញ ដើម្បីរក្សាទុកស្ថានភាពព្រៃឱ្យនៅដដែល ហើយប្រភេទឈើដែលគាត់ត្រូវដាំនោះគឺប្រភេទឈើក្រៅស្រុក ឬឈើក្នុងព្រៃធម្មជាតិរបស់វា ខ្ញុំគិតថាវាគឺជាការដោះស្រាយគ្នានៅក្រោយទៀត តែចំពោះនៅកន្លែងដទៃ ដូចខ្ញុំលើកឧទាហរណ៍ជាក់ស្តែងនៅរតនៈគីរី ស្រុក វើនសៃ និង ស្រុក តាវែង ដែលខ្ញុំជាអ្នកជំនាញផ្នែកបរិស្ថាន អញ្ចឹងនិយាយអោយជាក់ស្តែង ដូចជានៅអូរ **ពាផ្លាយ** ជាអូរមួយធំមានទឹកជាអចិន្ត្រៃយ៍ អញ្ចឹងយើងទុកព្រៃនៅតាមដងអូរនោះចំងាយ១៥០ម៉ែត្រ ហើយយើងចាត់ទុកថាវាជាគំរូមួយ។ តែដោយក្រុមហ៊ុនទាំង០៣នេះចាប់ផ្តើមមុនគេ ហើយគាត់មិនបានស៊ីជំរៅលើបញ្ហានេះ ធ្វើអោយមានការខូចខាតដូចដែលបានជំរាបជូនខាងលើមកអញ្ចឹង។ ដូចនេះខ្ញុំសូមអស់យោបល់ត្រឹមនេះ ដើម្បីទុកអោយអស់លោកមានការលើកជាសំនួរ ដើម្បីខ្ញុំបាទបំភ្លឺជូនអង្គប្រជុំបន្ថែមទៀត ។

**ឯកឧត្តម អ៊ុក សំអន** : ក្រោយពីការពិពិណនា របស់កុងស៊ុលតង់រួចមក បើមានចំណុចត្រង់ណាមិនទាន់យល់ច្បាស់សុំឱ្យសមាជិកអង្គប្រជុំចូលរួមផ្តល់យោបល់ ដើម្បីឱ្យក្រុមងារធ្វើការញ្ជាក់បន្ថែមលើការងារនេះ ព្រោះនេះជាការងារដែលយើងទាំងអស់គ្នា ត្រូវមានការចូលរួមសហការគ្នា ឱ្យស្អិតរមួត ដើម្បីដោះស្រាយនៅរាល់បញ្ហាដែលកើតមានចំពោះមុខ និងបញ្ហាដែលនឹងអាចកើតមាននៅពេលខាងមុខផងដែរ ដូចនេះសុំឱ្យអង្គប្រជុំចូលរួមមានយោបល់។

**លោក សុទ្ធ មារី** នាយផ្នែករដ្ឋបាលព្រៃឈើកំពង់ធំ: ជាបឋមសូមគោរពដល់ឯកឧត្តមប្រធាន អង្គប្រជុំព្រមទាំងអស់លោកដែលមានវត្តមាននៅទីនេះ ចំពោះខ្ញុំការងារនេះខ្ញុំទើបតែទទួលថ្មីក្នុងរយៈពេល៣ខែនេះទេ ចំពោះខ្ញុំមិនមានយោយល់អ្វីជំទាស់នោះទេ ដូចលោកនាយកកុងស៊ុលតង់បានបកស្រាយអម្បាញ់មិញនេះ គឺថាអង្ករបានក្លាយទៅជាបាយហើយ ចំពោះទិដ្ឋភាពរបស់ក្រុមហ៊ុនទាំង៣ហ្នឹង អញ្ចឹងខ្ញុំសូមមានមតិចូលរួមថា អំពីបញ្ហាផលប៉ះពាល់សង្គមនេះគឺមានភាពធ្ងន់ធ្ងរណាស់ ហើយចំពោះមុខនេះថ្មីនេះដូចលោកនាយកកុងស៊ុលតង់បានបានលើកអញ្ចឹង គឺ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី ក្រសួងកសិកម្ម ថ្នាក់ដឹកនាំផ្នែករដ្ឋបាលព្រៃឈើ ជាច្រើននាក់ទៀត បានដាក់បញ្ហាមកលើការងារនេះ។ ដែលបញ្ហានេះហាក់ ដូចដាក់កំហុសមកលើតែមន្ត្រីដែលអនុវត្តការងារនៅកន្លែងនេះ ព្រោះមិនបានធ្វើការណែនាំចង្អុលបង្ហាញ ដល់ក្រុមហ៊ុនធ្វើការការពារតំបនប់ព្រៃរក្សាទុកទាំងនោះ ធ្វើអោយតំបន់រក្សាទុកក្នុងដីសម្បទានទាំងអស់នោះមានការកាប់រានពីសំណាក់ប្រជាជនមួយចំនួន ដូចជាព្រៃរក្សាទុកតាមដងអូរនោះ អញ្ចឹងកន្លងមកការងារនេះខាងខ្ញុំក៏មានវិធានការរួចហើយដែរ ក្រោយពីមានការបញ្ជារបង្ហាញពីពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្មមកនោះ គឺអោយចាត់មន្ត្រីយើងសហការជាមួយក្រុមហ៊ុន ដើម្បីស្រង់ស្ថិតិ ប្រជាពលរដ្ឋដែលពាក់ព័ន្ធនៅតំបន់ព្រៃរក្សាទុករបស់ក្រុមហ៊ុននោះ ដើម្បីយើងឈានទៅរកការវិធានការជាក់លាក់មួយ តែទោះជាយ៉ាងណា ត្រូវតែមានការសហការសុំយោបល់ពីអាធរដែនដីជាមុនសិន ដើម្បីធ្វើការសុំដោះស្រាយ ចំពោះបញ្ហានេះយើងមាន

ការព្រួយបារម្ភណាស់អំពីព្រៃរក្សាទុករបស់ក្រុមហ៊ុន រហូតថ្មីនេះក្រសួងមានការចេញជាលិខិតមួយអោយដល់ក្រុមហ៊ុននេះមានការរំលឹក និងការយកចិត្តទុកដាក់ឱ្យបានខ្ពស់ អំពីតំបន់ព្រៃរក្សាទុកទាំងនោះ អញ្ចឹងដោយមានការចូលរួមរបស់ជំនាញក្នុងការចុះទៅពិនិត្យជាក់ស្តែងព្រៃរក្សាទុកទាំងនោះ មានទិដ្ឋភាពទូទៅដូចជាអ្វីដែលខាងកុងស៊ុលតង់បានលើកឡើងមកអញ្ចឹង គឺថាអង្គបានក្លាយជាបាយអស់ទៅហើយ ខ្ញុំមិនដឹងត្រូវនិយាយរបៀបណាទេ ដូចជាផលប៉ះពាល់ទីជំរាលអី គឺមិនដឹងថាជាត្រូវនិយាយយ៉ាងម៉េចទេ ប៉ុន្តែគ្រាន់តែថាអ្វីដែលយើងមានសេសសល់សព្វថ្ងៃ គឺយើងត្រូវរួមគ្នាការពារកំឱ្យមានបាត់បង់បន្តទៅមុខទៀត ហើយយើងត្រូវមានវិធានការមួយដាក់បន្ទុកទៅលើក្រុមហ៊ុនដើម្បីរកដំណោះស្រាយរួមគាថាយើងត្រូវធ្វើយ៉ាងណាទៀត ។

**ឯកឧត្តម អ៊ុក សំអន** :យើងកត់សំកាលឃើញថាការប៉ះពាលនោះ ទីមួយការចូលទៅធ្វើការកាប់រានរបស់ប្រជាពលរដ្ឋនៅក្នុងតំបន់។ ទី២ គួរជាការចូលរួមកាប់បំផ្លាញពីសំណាក់មន្ត្រី ឬប្រជាពលរដ្ឋដែលមានមុខការ នៅកន្លែងនោះផងដែរ អាចមានកងកំលាំងប្រដាប់អាវុធក៏មានដែរ។ ទី៣ ដូចជាកន្លែងខ្លះក្រុមហ៊ុនខ្លួនឯងបានឈូសជ្រុល ឧទាហរណ៍ច្បាប់កំណត់ថាទុក១០០ម៉ែត្រ តែក្រុមហ៊ុនឈូសជ្រុលរហូតដល់មាត់ច្រាំងហើយនៅកន្លែងខ្លះមានឈូសឈើហើយតែអត់ដាំក៏មានដែរ នេះខ្ញុំកត់សំគាល់ឃើញប៉ុណ្ណោះ តែចំណុចល្អឃើញថាក្រុម ហ៊ុនក្រោយពីបាន(សជណ) ហើយក្រុមហ៊ុនចាប់ផ្តើមមានសកម្មភាពឈូសឆាយដាំមែន ដូចនេះចំពោះផលប៉ះពាល់បរិស្ថានយើងដោះស្រាយជាមួយក្រសួង ហើយផលប៉ះពាល់នឹងសង្គមយើងដោះស្រាយជាមួយនិងសមត្ថកិច្ច ចំពោះបច្ចេកទេសយើងត្រូវរក្សាទុកចន្លោះប៉ុន្មាន១ ចំពោះព្រៃរក្សាទុកនោះដូចជាព្រៃស្រោងមិនមែនក្រុមហ៊ុន គិតថាកាត់ទុកហើយមិនមែនជារបស់ខ្លួនធ្វើអាជីវកម្មខ្លួនមិនទទួលខុសត្រូវនោះទេ ក្រុមហ៊ុនត្រូវមានកត្តព្វកិច្ចក្នុងការថែរក្សាព្រៃនោះឱ្យបានគង់វង្ស បញ្ចៀសទាំងអគ្គីភ័យទាំងផលប៉ះពាល់នានាអញ្ចឹងកន្លង មកដោយសារការចូលកាប់រានដោយប្រជាពលរដ្ឋក្រុមហ៊ុនយល់ថាគាត់មិនមានអំណាចឬសិទ្ធិក្នុងការទប់ស្កាត់ ទើបធ្វើឱ្យប្រជាពលរដ្ឋចេះតែចូលទៅកាប់រាន អញ្ចឹងចំពោះការងារនេះយើងត្រូវតែរិះរកវិធានការ។ ចំពោះផលប៉ះពាល់បរិស្ថានក្រុមហ៊ុនត្រូវជ្រើសរើសដូចជាព្រៃរំដោះ ព្រៃស្រោងគឺមិនអាចចាត់ទុកខ្លួនថាជាព្រៃសំរាប់ធ្វើអាជីវកម្ម គឺត្រូវមានកាតព្វកិច្ចក្នុងការថែរក្សាការពារពីអគ្គីសភ័យ និងការប៉ះពាល់នានា អញ្ចឹងចំពោះ ប្រជាបលរដ្ឋដែលមានការប៉ះពាល់ ក្រុមហ៊ុនមិនមានអនុភាពខាងផ្លូវច្បាប់ ឬក៏ឥទ្ធិពលអវិជ្ជមានធ្វើអោយប្រជាពលរដ្ឋចេះតែចូលទៅកាប់រាន អញ្ចឹងគឺករណីនេះគឺយើងសំគាល់ឃើញផងដែរការងារនេះនៅពេលដែលត្រឡប់ទៅរកវិធានការសារជាថ្មីវិញគឺថាក្រុមហ៊ុនត្រូវទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាល ឧទាហរណ៍ថាពាក់ព័ន្ធជាមួយ និងប្រជាពលរដ្ឋ ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរ តើត្រូវដេញ ឬក៏ចាត់វិធានការនៅទីនោះផ្ទាល់តែម្តង តែបើពាក់ព័ន្ធអ្នកដែលនៅក្រុមហ៊ុននេះផ្ទាល់ហើយស្ងាត់ច្រៀបមិន ឃើញធ្វើអីសោះនោះ ក្រុមហ៊ុនត្រូវសហការជាមួយជំនាញពិនិត្យឡើងវិញនូវអ្វីដែលបានប៉ះពាល់រួចទៅហើយគួរប៉ះប៉ូវឡើងវិញតាមរបៀបយ៉ាងម៉េច? ដូចនេះសំឱ្យជំនាញរៀបចំរបាយការណ៍ឡើងទៅសាមីក្រសួងផ្ទាល់ ដើម្បីមាន

Draft

វិធានការផ្លូវច្បាប់នេះគឺខ្ញុំចាប់អារម្មណ៍ផ្ទាល់នូវអ្វីដែលខ្ញុំបានតាមដាននឹងឃើញផ្ទាល់ ហើយចំពោះអ្វីដែលបានលើកឡើងនេះ គឺវាត្រឹមត្រូវទេ ហើយបើមានអ្វីជាផ្សេងទៀតសូមលើកជាអនុសាសន៍មក ។

**លោក អោង ប៊ុនធឿន** អនុប្រធានមន្ទីរបរិស្ថានខេត្តៈ ចំពោះការវាយតំលៃហេតុប៉ះពាល់ បរិស្ថាននោះក្រុមហ៊ុនប្រាកដជាបានចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាលរួចហើយនៅក្នុងកិច្ចការពារបរិស្ថាននោះ ដូចជាថាការការពារព្រៃដែលត្រូវរក្សាទុកនៅតំបន់ការការការហូច្រោះ ផ្ទៃដីព្រៃបំរុងទុកអ្វីជាដើមនោះដោយករណីការឈូសឆាយរបស់ក្រុមហ៊ុនជាដើម ។ តែដោយឡែកការធ្វើបទបង្ហាញស្តីពីរបាយការណ៍វាយតំលៃហេតុប៉ះពាល់និស្ថាននេះមិនបានសរសេរ លំអិតអំពី ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយនោះទេ ដូចនេះសុំក្រុមហ៊ុនធ្វើការសេរសេរឱ្យបានច្បាស់ត្រូវតែគិតព្រោះកន្លងមកក្រុមហ៊ុនបានធ្វើឱ្យ ប៉ះពាល់ដល់បរិស្ថានរួចមកហើយ ដូចនេះតើមានវិធានការយ៉ាងណាទៀតនៅពេលអនាគតដែលវានឹងអាចមានផលប៉ះពាល់តទៅទៀតនោះ ។ ដូចនេះហើយខ្ញុំសូមសំណូមពរឱ្យសុំអោយបញ្ចូលឱ្យបានច្រើនក្នុងការកាត់បន្ថយការប៉ះពាល់បរិស្ថាន និងការបំពុលទឹកជាដើម ។

**បណ្ឌិត លី សុពណ៌-មុនី** : ខ្ញុំសូមបន្ថែមនូវអ្វីដែលបងខាងមន្ទីរបរិស្ថានបានលើកឡើង ផលប៉ះពាល់ក្នុងករណីកៅស៊ូមានការបែងចែក មុនពេលប្រតិបត្តិការ ក្នុងរយៈពេលប្រតិបត្តិការណ៍ដាំដុះ និងនៅពេលប្រតិបត្តិការប្រមូលផល ខ្ញុំមិនទានបានពត៌មានទេថា នៅក្នុងឆ្នាំនេះឬពាក់កណ្តាលឆ្នាំក្រោយសាងសង់រោងចក្រ ហើយយើងឃើញថា ផលប៉ះពាល់ពីក្រសួងមួយទៀត បើសិនជាមានការសាងសង់រោងចក្រកែច្នៃ ព្រោះអីកាត់ត្រូវប្រើជាតិគីមី អាស៊ីត ឬជាតិគីមីអីផ្សេងទៀតដែលជាប់ពាក់ព័ន្ធនេះ ដើម្បីធ្វើអោយកៅស៊ូកក ក្លាយទៅជាកៅស៊ូក្រែបនេះឯង នៅក្នុងច្បាប់យើងនេះគឺតំរូវអោយគាត់ធ្វើ EIA មួយដាច់ដោយឡែក នៅពេលដែលគាត់សាងសង់រោងចក្រកៅស៊ូក្រែប ពីព្រោះអីវាមានសំណល់រាវ ហើយនឹងសំណល់រឹងដែលត្រូវចេញពីរោងចក្រនេះ ពេលដែលយើងរៀបចំវាយតំលៃសំរាប់ការវាយតំលៃកៅស៊ូនេះ អញ្ចឹងហើយបានជាយើងបកស្រាយថា សំណល់រាវ ហើយនឹងសំនល់រឹងទុកដាក់យ៉ាងម៉េច ហើយពេលនេះអាចឈានដល់ការវាយតំលៃដីនេះដោយ ពេញលេញ ខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងនោះ សូមអគុណ ។

**ឯកឧត្តម អ៊ុក សំអន** : នៅពេលនេះការធ្វើបទបង្ហាញ លើរបាយការចុះសិក្សាស្រាវជ្រាវរបស់ក្រុមការ ងារចុះទៅសិក្សាទៅបរិស្ថាន តាមរយៈរូបភាពដែលធ្វើការបង្ហាញ ក្នុងទីតាំងរបស់ក្រុមហ៊ុន ហើយអាចមាន បញ្ហាជាច្រើនទៀតដែលយើងត្រូវបំពេញបន្ថែមដើម្បីធ្វើយ៉ាងណាឱ្យរបាយការណ៍នេះអាចដាក់ចូលទៅប្រជុំថ្នាក់ជាតិអាចទទួលយកបាន នឹងមានតំលៃការពារមិនឱ្យមានការខូចខាត នឹងប៉ះពាល់ដល់បរិស្ថានធ្ងន់ធ្ងរនៅពេលអនាគត សុំឱ្យអង្គប្រជុំមានយោបល់បន្ថែមទៀត ។

Draft

**លោក ហុង សេងហាក់** មន្ត្រីការិយាល័យផែនការកសិកម្មខេត្ត: ខ្ញុំមានយោបល់មួយចំនួនទាក់ទង ទៅនឹងការសិក្សាវាយតំលៃ ដែលនៅក្នុងសេចក្តីសន្និដ្ឋានអត់បានពិនិត្យឃើញ ថាតើក្រោយពីការឈូសឆាយព្រៃ នេះទៅហើយជំនួសដោយព្រៃកៅស៊ូវិញ តើមានការកាត់បន្ថយការប៉ះពាល់ទៅលើគំរប់ព្រៃឈើដែរឬទេ ? ហើយបើមានការប៉ះពាល់ តើរយៈពេលប៉ុន្មានដែលអាចស្តារឡើងវិញនៅផលប៉ះពាល់ទាំងនោះ? តើក្រុមហ៊ុនមានបានធ្វើការប្រៀបធៀបទេ? សូមអគុណ។

**បណ្ឌិត លី សុពណ៌-មុនី** :ជាទូទៅបានដូចខ្ញុំបានជំរាប់ ខ្ញុំអាចបកស្រាយ ជូនបានដោយនេះជាការវាយតំលៃ ផលប៉ះពាល់បរិស្ថានដំបូង មិនមែនជាផលប៉ះពាល់បរិស្ថានពេញលេញទេ ដូចនេះការគណនាដូចជាមានការ លំបាកដូចខ្ញុំបានលើកជាឧទាហរណ៍នៅខាងដើមរួចហើយថា ដោយសារពេលដែលក្រុមការងារខ្ញុំមកដល់គឺព្រៃវា អស់ហើយ អញ្ចឹងបើយើងចង់សិក្សាពេញលេញ គណនាពីសន្និធិកាបូន មុនពេលដែលក្រុមហ៊ុនធ្វើការឈូសឆាយដាំដុះកៅស៊ូ ក៏យើងអត់ដឹងដែរ ព្រោះយើងអត់មានទិន្នន័យទាំងនោះទាលតែសោះ ក៏ប៉ុន្តែបើសិនជាខ្ញុំលើកជារួមថា ជាទូទៅបើសិនជា ទិន្នន័យខ្ញុំមាននៅមណ្ឌលគិរី នៅឆ្នាំទី១១ សន្និធិកាបូនរបស់ព្រៃកៅស៊ូគឺវាឡើងស្មើនឹងព្រៃធម្មជាតិខ្ទង់១៤០តោនជាង នៅឆ្នាំទី១១គឺសន្និធិកាបូនរបស់កៅស៊ូឡើងដល់ទៅ១៥០តោន ដោយឡែកដល់ឆ្នាំទី៣០ សន្និធិកាបូនវាឡើងទៅដល់៣.៨៩ដង ច្រើនជាងសន្និធិកាបូនរបស់ព្រៃធម្មជាតិ ដូចនេះយើងគិតថាប្រសិន បើយើងឈូសព្រៃដាំកៅស៊ូ យ៉ាងហោចនៅក្នុងឆ្នាំទី១១ បានសន្និធិកាបូននៅក្នុង ព្រៃកៅស៊ូនេះគឺវាស្មើរនឹងសន្និធិកាបូននៅក្នុង ព្រៃធម្មជាតិមុនពេលយើងធ្វើការអភិវឌ្ឍន៏ក្នុងរយៈក្រោយ ១១ឆ្នាំមុនពេលឈូសឆាយនិងដាំដុះ ។

**ឯកឧត្តម អ៊ុក សំអន** : ការប្រៀបធៀបនេះជាមួយនឹងព្រៃស្រោង ឬព្រៃរិចរិល ព្រៃឡង់ ឬជាមួយនឹង ព្រៃដែលក្រុមហ៊ុន **មៀង លីហេង** ដែលដកហូត ហើយ នៅពេលដែលយើងឈូសឆាយ យើងបាត់បង់នូវសន្និធិកាបូនប៉ុន្មានឆ្នាំដូចយើងនិយាអម្បាញ់មិញថាទាល់តែឆ្នាំទី១១ ទើបវាមានសន្និធិការបូនឡើងវិញដល់ពេលដាំចាប់ពី៣០ឆ្នាំទៅយើងគុណ២-៣ដងមកវិញ។

**បណ្ឌិត លី សុពណ៌-មុនី** : ករណីព្រៃនៅខេត្តកំពង់ធំយើងរបស់ក្រុមហ៊ុនទាំងបីនេះ ខ្ញុំគិតថាសន្និធិកាបូន នៅតិចជាង១០០តោនអញ្ចឹងនៅក្នុងឆ្នាំទី១១ ចំពោះសន្និធិកាបូនរបស់ព្រៃកៅស៊ូវា២ដងច្រើនជាងព្រៃរេចរឹលក្នុងពេលបច្ចុប្បន្ន ហើយខ្ញុំមិនទាន់មានឱកាសទៅសិក្សាសន្និធិកាបូននៅក្នុងព្រៃ ឡង់ទេ ប៉ុន្តែយើងលើកឧទាហរណ៍ថា ព្រៃឡង់មួយនៅក្នុងដីព្រៃមួយហិកតាអាចមានកៅស៊ូ ឈើទាលរហូតដល់ ៣២០ដើម ព្រៃឡង់ដែលល្អមែនទែន បើសិនជាឈើទាល ៣០០ដើម អញ្ចឹងសន្និធិកាបូន របស់គាត់អាចឡើងដល់ជាង ១០០០តោន អញ្ចឹងជាទូទៅព្រៃដែលយើងដាំមិនថាព្រៃណា ឬក៏ព្រៃនៅប្រទេសណាទេ បើសិនជាយើងយក

សន្និធិកាបូនប្រៀបធៀបជាមួយនឹងសន្និធិកាបូនរបស់ព្រៃឡង់គឺវាមិនអាចស្មើគ្នាទេ ព្រៃដែលដាំវាអាចមានសន្និធិកាបូន តិចជាង៣ដងនៃព្រៃឡង់ ។

**លោក អោង ប៊ុនធឿន** អនុប្រធានមន្ទីរបរិស្ថានៈ នៅក្នុងរបាយការណ៍យើងឃើញមានការទាក់ទងនឹងសត្វព្រៃ នៅពេលដែលមាន ការឈូសឆាយព្រៃឈើទៅវាទាក់ទងនឹងការបំលាស់ទីនៃការបំលាស់ទីរបស់សត្វព្រៃ តើចំពោះការវាយតំលៃផលវិជ្ជមាននៅពេលដែលព្រៃកៅស៊ូមានការស្តារឡើងវិញ តើសត្វព្រៃមានការប្រែប្រួលត្រឡប់ឡើងវិញ ឬអាចកកើតនៅក្នុងនោះបានដែរ ឬយ៉ាងណា ?

**បណ្ឌិត លី សុពណ៌-មុនី :** ជាទូទៅនៅក្នុងព្រៃកៅស៊ូមានតិច ខុសពីព្រៃដូងប្រេង ឬព្រៃអ្វីផ្សេងទៀត នៅក្នុងព្រៃដូងប្រេង ស្វា ជ្រូក ឈ្លូសអាចមានមកនៅបាន ប៉ុន្តែនៅក្នុងព្រៃកៅស៊ូសត្វទាំងអស់នេះមិនមកទេ ព្រោះនៅក្នុងព្រៃនេះវាមិនមានចំណីអាហារអ្វីសំរាប់ទាក់ទាញវាមកទេ ហើយជាទូទៅយើងនិយាយអំពីបំរែបំរួលនៃការធ្វើបំលាស់ទីរបស់សត្វព្រៃ គឺយើងមើលទៅសកម្មភាពការអភិវឌ្ឍន៍ផ្សេងៗ ខ្ញុំលើកឧទាហរណ៍យ៉ាងសាម័ញ្ញគឺរ៉ែមាស ជាទូទៅរ៉ែមាសនៅប្រទេសយើង ហៅថាភាសាអង្គ្លេស Minesub បានន័យថា យើងជីករូងពី ២០ម៉ែត្រ រហូតទៅដល់ ៨៥ម៉ែត្រ នៅបូស៊ុបទ្រុប នៅឧត្តរមានជ័យ អញ្ចឹងទោះបីជាជីកទៅក្រោម ៨០ម៉ែត្រ ក្តីនៅពេលដែលយើងដាក់ម្សៅផ្ទុះវាញ័រ ជាទូទៅបើយើងទៅរស់នៅកន្លែងនេះមនុស្សក្តីសត្វព្រៃក្តី មានគ្រឿងចក្រ ដូចនេះហើយវាធ្វើអោយសត្វ ព្រៃរអើលក្នុងរយៈពេលខ្លីនេះ គឺវាវិវឌ្ឍន៍ទៅជាសភាវគតិមួយ ថាមកកន្លែងនេះមិនបានទេ ហើយវាក៏បំលាស់ទីទៅ២០-៣០គីឡូម៉ែត្រ ដល់ចំណុចណាមួយដែលមានសុវត្ថិភាព ប៉ុន្តែរយៈពេលមួយអាចថា១០ឆ្នាំឬមួយ២០ឆ្នាំក្រោយនៅពេលរ៉ែនោះគេយកចប់ត្រូវបានបិទអណ្តូងរ៉ែ អញ្ចឹងបានសត្វព្រៃមកហើយរស់នៅដូចធម្មតាវិញ ដោយឡែកនៅក្នុងព្រៃនេះដើមឡើយមានដំរី មានខ្លា មានសត្វផ្សេងៗជាច្រើនទៀតហូរហែរ ។ ប៉ុន្តែនៅពេលដែលយើងបំផ្លាញមជ្ឈដ្ឋានរស់នៅរបស់វាហើយនោះ ទោះបីជា ១៣ ឆ្នាំក្រោយ កៅស៊ូឡើងទៅដល់ ១៧-១៨ ម៉ែត្រ ហើយគំរប់ព្រៃមានឡើងជិតវិញក៏សត្វព្រៃទាំងអស់នេះមិនអាចមកបើមានមកគឺតិចតួចណាស់មានឈ្លូស ស្វា ជួនកាលគាត់ផ្អើលមកពីណាអីមកមួយភ្លែតក៏រត់ ចេញវិញបាត់ទៅ ពីព្រោះអីនៅកន្លែងនេះវាមិនជាជំរករសមស្របសំរាប់ពួកវារស់នៅ ។

**លោក ហុង សេងហាក់** មន្ត្រីការិយាល័យផែនការកសិកម្មខេត្តៈ ខ្ញុំបានសូមគោរពដល់ ឯកឧត្តមលោកជំទាវទាំងអស់ដែលមានវត្តមាននៅក្នុងអង្គប្រជុំនេះ ខ្ញុំបាទមក ពីមន្ទីកសិកម្ម ខ្ញុំមានការកត់សំគាល់ទៅលើរបាយការណ៍នេះគឺមានចំណុចមួយ ពាក់ព័ន្ធនឹងក្រុមហ៊ុន **បា រាំ និង វៀក វា** អញ្ចឹង គួរតែមានចំណុចណាមួយដែលបានថែង និងបញ្ជាក់ របស់ក្រុមហ៊ុន **បា រាំ** យើងបានទទួលលិខិតប្តូរនាមករណ៍ ហើយឬយ៉ាងម៉េច ឬមួយគឺយើងមិនទាន់បានកត់ត្រាចូលនៅក្នុងរបាយការណ៍ ហើយយើងឃើញថាវាពាក់ព័ន្ធនឹងក្រុមហ៊ុន

Draft

**បា រ៉ា** នេះ យើងនែកឃើញនៅមានឈ្មោះចាស់នៅឡើយ ដូចនេះមិនឃើញមានបញ្ជាក់ឃ្លាណាមួយដែលបញ្ជាក់ថាក្រុមហ៊ុន **បា រ៉ា** និងក្រុមហ៊ុន **ភឿក វា** ធ្វើការផ្ទេរទៅជាក្រុមហ៊ុនណាមួយ ព្រោះអីពេលខ្លះយើងសរសេរ **បា រ៉ា** ពេលខ្លះយើងសរសេរ **អេច អឹម អេច** ពេលខ្លះយើងសរសេ **ភឿក វា** ពេលខ្លះយើងសរសេរ **មាន រិទ្ធី** អញ្ចឹងយើងគួរតែមានឃ្លាណាមួយ ដែលចង់តែមួយហើយ លើកក្រោយយើងសរសេរយក ក្រុម ហ៊ុនមួយជាគោលហើយពាក់ព័ន្ធនឹង ប្រសាសន៍ឯកឧត្តម អស់លោកខ្ញុំមានការកត់សំគាល់ ឃើញថា ជាការពិតយើងឃើញថាក្រុមហ៊ុនទាំងបីនេះ បានឈូសឆាយនិងដាំ ស្ទើរទាំងអស់ទៅហើយបើតាមរបាយការណ៍គឺ នៅសស់ផ្ទៃដីមិនដល់ ២០០០ ហិកតាទេនេះជាចំណុចទី១ ហើយចំណុចទី២ និយាយអំពីចំណុចប៉ះពាល់បរិស្ថានដែលយើងមើលឃើញសព្វថ្ងៃនេះគឺ មានផលប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ហើយផលប៉ះពាល់សង្គមនេះ គឺយើងបានជួបប្រទះហើយនឹងបានធ្វើការដោះស្រាយជាបន្តបន្ទាប់ ដោយឡែកចំពោះផលប៉ះពាល់បរិស្ថានយើងគិតថា មិនទាន់ឃើញថាការវាយតំលៃនេះ រៀបរាប់ផលប្រយោជន៍យ៉ាងណានោះទេ ផ្តោតទៅលើការបំរែបំរួលអាកាសធាតុ ដែលយើងឃើញថា វាក្តៅហើយភ្លៀង នេះជាចំណុចមួយនៃការវាយតំលៃផលប៉ះពាល់បរិស្ថាន ហើយចំណុចទី២ គឺការឈូសខុសការគំណត់ ខុសនិយាមកាដែលកំណត់នៅក្នុងផែនការមេ និងកិច្ចសន្យា អញ្ចឹងជាយោបល់របស់ខ្ញុំ យើងអាចចាត់ទុកថាជាអនុសាសន៍ នោះគួរតែឱ្យមានសិក្សាលំអិតនៅចំណុចដែលក្រុមហ៊ុនបានអនុវត្តន៍ ដោយជាក់ស្តែង ហើយប្រៀបធៀបនិយាមកាដែលមានចែងនៅក្នុងកិច្ចសន្យានិងផែនការមេនេះគឺជាចំណុចទី១។ ក្នុងចំណុចទី២ ដូចប្រសាសន៍លោកអនុប្រធានទីប្រធានបរិស្ថាន សូមលោកនាយក អាចសរសេរ អោយបានលំអិតនៅរបាយការណ៍ដែលយើងបានឃើញជាក់ស្តែង នូវចំណុចដែលខុសពីផែនការមេ យើងសរសេរនេះមានន័យថា យើងមិនមែនមានបំណងធ្វើបាបក្រុមហ៊ុនដែលបានអនុវត្តន៍ខុសទេ ប៉ុន្តែនេះចាត់ទុកថាជាមេរៀនសិក្សា ឬជាបទពិសោធន៍មួយ សំរាប់ក្រុមហ៊ុនក្រោយៗទៀត ហើយមានន័យថាគួរតែមានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន មុននិងការអនុញ្ញាត ឱ្យធ្វើសម្បទានវិនិយោគ ។

**បណ្ឌិត លី សុពណ៌-មុនី** : ករណីពាក់ព័ន្ធនិងលិខិតបទដ្ឋានប្តូរឈ្មោះនាមករណ៏ក្រុមហ៊ុន ខ្ញុំសូមមិនមានការបកស្រាយនៅចំណុចទីមួយទេពីព្រោះអី ក្រុមហ៊ុន **បា រ៉ា** ហើយនិង **ភឿក វា** គាត់កំពុង តែធ្វើការជាមួយក្រសួងកសិកម្ម ដើម្បីឈានទៅរកការផ្លាស់ប្តូរឈ្មោះអោយបានសមស្រប ទី២ក្រសួងបិស្ថាន ក្រសួងកសិកម្ម ជាពិសេសរាជរដ្ឋាភិបាល គឺមានការអនុគ្រោះចំពោះសហព័ន្ធកៅស៊ូ បើសិនជាក្រុមហ៊ុនក្នុងស្រុកឬក្រុមហ៊ុនដ៏ទៃទៀតគឺមិនអាចចាប់ផ្តើមបានមុនពេលដែលរបាយការណ៍នេះ ឆ្លងហើយអនុម័តពីរាជរដ្ឋាភិបាលទេ ធម្មតាមុនប្រតិបិត្តការឈូសឆាយនោះ ត្រូវចុះទៅធ្វើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានហើយដាក់ឆ្លង ៣ដង នៅក្រសួងបរិស្ថានសិនមានថ្នាក់បច្ចេកទេសនាយកដ្ឋាន ថ្នាក់ដឹកនាំក្រសួង ហើយនិងថ្នាក់អន្តរក្រសួង ក្រោយការចូលរួមយោបល់ដកស្រង់គំនិតយកមកកែសំរួលឃើញថាសមស្របតាមនេះអស់ហើយ ស្នើទៅរាជរដ្ឋាភិបាល ដើម្បីស្នើសុំឯកភាពពីរាជរដ្ឋាភិបាលក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាលហើយក្រសួង

បរិស្ថាន រៀបចំចុះកិច្ចសន្យាដោយឡែកមួយជាមួយក្រុមហ៊ុន ថាក្រុមហ៊ុនពិតជា អនុវត្តន៍ទៅតាមអ្វីដែលជាវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន និង សង្គម ដូចដែលកុងស៊ុលតង់រៀបចំហ្នឹង។ ប៉ុន្តែដល់សហព័ន្ធកៅស៊ូ វៀតណាម និងរាជរដ្ឋាភិបាលកម្ពុជាមានការយោគយល់ មានការយោគយល់គ្នារវាងប្រមុខថ្នាក់ដឹកនាំទាំងពីរ ហើយសហព័ន្ធកៅស៊ូវៀតណាមនេះ គឺធ្វើជាក់ស្តែងខុសពីក្រុមហ៊ុនដទៃ បើយើងនិយាយឱ្យពិតប្រាកដតាមការអនុវត្តន៍ជាក់ស្តែងក្រុមហ៊ុន មានការយឺតយាវបន្តិចមែនពីដើមទី ប៉ុន្តែនៅក្នុងឆ្នាំនេះ គឺក្រុមហ៊ុននឹងសំរេច បានការដាំដុះរួមទូទាំងប្រទេស សរុបបានជាង៥០.០០០ហិកតា។ ហើយនិយាយថាផែនការរបស់សហព័ន្ធកៅស៊ូដូចជាមានមហិច្ឆិតាខ្ពស់ ដោយក្រុមហ៊ុនចង់ដាំអោយលឿននៅអ្វីដែលចង់ ដល់ពេលអញ្ចឹងទិសដៅគាត់ គឺដល់ឆ្នាំ ២០១២ ដាំអោយ អស់ដី១០.០០០០ហិកតា ដូចនេះពួកយើងដែលជាក្បាលម៉ាស៊ីននៅខាងលើ កំពុងតែឆ្ងល់ថា យើងត្រូវប្រមូលកំលាំងយ៉ាងម៉េច ដើម្បីអោយឆ្នាំក្រោយដាំបាន៥០.០០០ហិកតានេះ ដោយសារមានលក្ខណៈពិសេសនេះហើយ ទើបបានក្រសួងកសិកម្ម និងក្រសួងបរិស្ថាន មានការយោគយល់ច្រើនដល់ក្រុមហ៊ុន។ ព្រោះនៅពេលដែល ក្រុមហ៊ុនទទួលបានដីសម្បទានពីរាជរដ្ឋាភិបាលមកហើយគាត់មិនទុកបង្កកដីនោះ ឬតំកល់ទុកលក់យកចំណេញផ្ទាល់ខ្លួនទេ គឺគាត់យកមកអនុវត្តន៍ការដាំដុះជាក់ស្តែងអញ្ចឹងបាន ចេះតែមានអនុគ្រោះ ខ្ញុំលើកសុំឧទាហរណ៍ ក្រៅពីដីកសិកម្ម មានក្រុមហ៊ុនមួយនៅស្នោងឆ្នាំនេះ **ស៊ី អ ស៊ី ខេ ២** នៅស្នោង ឆ្នាំនេះគាត់ដាំបានជាង ៤.០០០ហិកតា ហើយបើសិនជាក្រុមហ៊ុនតូចៗ នៅក្នុងស្រុកគឺអត់មានលទ្ធភាពសោះដូចជាឧកញ៉ា **អាន ម៉ាឌី** គាត់ដាំ១ឆ្នាំ៥០០អីប៉ុណ្ណោះ។ អញ្ចឹងមូលហេតុដែលបងខាងមន្ទីរបរិស្ថានលើកមកនោះ វាជាបញ្ហាថ្នាក់ជាតិ យើងនៅថ្នាក់ក្រោមមិនអារកាត់បានទេ ហើយបើដូចខ្ញុំនៅជាប់នឹងពួកគាត់ខ្ញុំដឹងមូលហេតុ គឺអញ្ចឹងយើងមាន តែការយោគយល់អនុគ្រោះ ដោយសារតែយើងយល់ឃើញថា ក្រុមហ៊ុនពួកគាត់យកដីទៅគឺធ្វើភ្លាម មូលហេតុនេះឯង។ បើសិនជាក្នុងករណីក្រុមហ៊ុនផ្សេងទៀតក្រសួងរក រឿងបាត់នេះទៅឈូសមិន ទាន់នឹងសារពើព័ណ្ឌបង់ព័ន្ធអីហូរហែរនោះគឺមិនមានទេ ។

**លោក អោច ប៊ុនធឿន** អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំៈ នៅក្នុងរបាយការនេះខាងតំណាងក្រុមហ៊ុនបានធ្វើការវាយតំលៃថា បើសិនជាមានការគ្រប់គ្រងបរិស្ថានឱ្យបានត្រឹមត្រូវនោះ ការបំពុលទឹកអីនោះវានឹងអាចមានការល្អប្រសើរអញ្ចឹង ទាក់ទងទៅនឹងបញ្ហាបំពុលបរិស្ថាននេះ តើខាងអ្នកចុះអនុវត្តន៍លើការងារនេះ?។

**បណ្ឌិត លី សុពណ៌-មុនី :** អញ្ចឹងយើងនិយាយអំពីកម្មវិធីអនុវត្តន៍តាមដានត្រួតពិនិត្យ និងវាយតំលៃផលប៉ះពាល់បរិស្ថាន ខ្ញុំលើកឧទាហរណ៍ដើម្បីអនុវត្តន៍នៃការនេះ ថវិកាសរុបដែលគ្រោងប្រើប្រាស់ក្នុងការអនុវត្តន៍ ផែនការគ្រប់គ្រងបរិស្ថានក្នុងរយៈពេល ៩ឆ្នាំ មានប្រមាណ ៣.៨០០.០០០ ថវិកានោះទីមួយប្រើទៅលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ទីពីរយើងមើលទៅលើការគ្រប់គ្រងតំបន់ទ្រនាប់ ហើយមូលនិធិដើម្បី

Draft

អភិវឌ្ឍន៍សហគមន៍ និងស្តារបរិស្ថាន ហើយអនុវត្តកម្មវិធីត្រួតពិនិត្យ និងវាយតំលៃ ហើយទី១ខ្ញុំ មិនលើកយកមកនិយាយនោះទេ មកពីពាក់ព័ន្ធទៅនឹងសាលារៀន ពាក់ព័ន្ធទៅនឹងផ្លូវថ្នល់ មណ្ឌលសុខភាពអីនោះជាហូរហែររបស់ក្រុមហ៊ុនមួយៗហ្នឹង។ អញ្ចឹងយើងមើលតំបន់គ្រប់គ្រងទ្រនាប់ យើងតំរូវឱ្យមានស្ថានីយ៍ល្បាតអចិន្ត្រៃយ៍០៣ ហើយនៅក្នុងស្ថានីយ៍នីមួយៗនោះ មានអ្នកល្បាត ២នាក់ ហើយមានមធ្យោបាយផ្សេងៗអីជាហូរហែរ ដើម្បីអោយពួកគាត់គ្រប់គ្រងអោយបានល្អ អញ្ចឹងមូលលិធិដើម្បីអភិវឌ្ឍន៍សហគមន៍មានប្រមាណជាមួយឆ្នាំ ២៥.០០០ ចំណែកឯខាងស្តារបរិស្ថានមួយឆ្នាំ ៣០.០០០ អញ្ចឹងនៅពេលដែលយើងកំណត់តើយើងធ្វើយ៉ាងម៉េច ឱ្យដឹងថាក្រុមហ៊ុនពិតជាអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានដូចដែលយើងបានកំណត់ជាទូទៅក្រុមហ៊ុន និមួយៗចាំបាច់ត្រូវមានបុគ្គលិកជំនាញបរិស្ថាន ដែលយើងហៅថា Local Environment Coordinator គឺអ្នកសំរបសំរួលខាងផ្នែកបរិស្ថានរបស់ក្រុមហ៊ុនផ្ទាល់តែម្តងម្នាក់ ហើយជារៀងរាល់ខែគាត់ត្រូវធ្វើរបាយការណ៍មកមន្ទីរ ហើយចំលងជូនទៅក្រសួង ហើយរៀងរាល់៣ខែម្តងក្រុមការងារក្រសួងត្រូចុះមកពិនិត្យនោះគឺនាយកដ្ឋាន EIA ហើយរៀងរាល់ ៦ខែម្តងគឺក្រុមអន្តរក្រសួងចុះមកត្រួតពិនិត្យ នៅពេលដែលក្រុម អន្តរក្រសួងចុះមកនោះចាំបាច់ (ធ្វើតេស) ត្រូវយកដី និងទឹកមកពិនិត្យ ប៉ុន្តែករណីដោយឡែកចំពោះដីកសិ-ឧស្សាហកម្មដាំកៅស៊ូ យើងមិនសូវចាប់អារម្មណ៍ប៉ុន្មានទេ ពីព្រោះអីយើងគិតថាជាការប៉ះពាល់កំរិតមធ្យមទាំងនៅពេលប្រតិបត្តការណ៍ដាំដុះ ទាំងនៅពេលដែលប្រមូលផល ហើយនៅពេលកែច្នៃគឺវានៅកំរិតមធ្យម ប៉ុន្តែប្រសិនបើគំរោងអភិវឌ្ឍន៍មួយវាមានផលប៉ះពាល់តិចឬមួយច្រើន វាអាស្រ័យទៅឆន្ទះរបស់សាមីវិនិយោគគិនហ្នឹង ឆន្ទៈនេះមានន័យម៉េច? ប្រសិនបើគាត់ឆន្ទះបរិស្ថាន ដូចនេះគំរោងគាត់ពីមានផលប៉ះពាល់ធ្ងន់មកមធ្យម ពីមធ្យមមកទាប ឬទាបមក គ្មានផលប៉ះពាល់សោះតែម្តង ដូចនេះទើបយើងគ្រាន់តែដាក់ថា ក្រសួងបរិស្ថាន និង អន្តក្រសួងជុំយទៅវិញ បើសិនជាគំរោងនេះមានផលប៉ះពាល់ធ្ងន់ធ្ងរ ឧទហរណ៍រ៉ែមាស ក្រៅពីក្រុមការងារអន្តរក្រសួង ត្រូវមានក្រុមអ្នកត្រួតពិនិត្យឯករាជ្យមួយទៀតដែលយើងហៅថា Indepen dent Monitoring body or Organization ដែលពួកគេទាំងនោះចុះមកសំខាន់គឺនៅលើ Test តែម្តង គឺនៅលើ ទឹក តើនៅក្នុងទឹកមានលោហៈធន់ធ្ងន់ មានពួក អាសេនិច ហើយបើទៅរ៉ែមាសនោះមានបារ៉ត មាននៅក្នុងបញ្ហា ស្យ៉ាណែត អីក៏អត់ ដែលជាទូទៅមានបង្ហាញនៅក្នុងផែនការមេទាំងអស់ ចំពោះរបាយការណ៍ EIA គឺសុទ្ធតែមានដូចគ្នាទាំងអស់ ។

**ឯកឧត្តម អ៊ុត សំអន** : ក្នុងការធ្វើបទបង្ហាញនៅពេលនេះ តើខាងក្រុមការងារ EIA ចង់បានអនុសាសន៍ក្នុងការឱ្យមានការប៉ះប៉ូវពីក្រុមហ៊ុនមកវិញឬយ៉ាងម៉េច ចំពោះក្រុមហ៊ុនដែលបានធ្វើការឈូសលើសផ្ទៃដីដែលបានកំណត់នេះ ដែលជាធម្មតាការងារនេះមានក្រសួងពីរដែលទទួលខុសត្រូវ ក្នុងនោះមានក្រសួងកសិកម្ម ដែលមានរដ្ឋបាលព្រៃឈើជាសេនាធិការផ្ទាល់ ហើយក្រសួងបរិស្ថានអ្នកតាមដានវាយតំលៃហេតុប៉ះពាល់បរិស្ថាន បើករណីក្រុមហ៊ុនមិនគោរពនូវគោលការរបស់ក្រសួងណាមួយនោះក្រុមហ៊ុនជាអ្នកទទួល

ដោះស្រាយជាមួយផ្លូវច្បាប់ទាំងនោះ ដូចយើងដឹងហើយករណីក្រុមហ៊ុន **ពាន បឿន** នេះនៅម្តុំភ្នំប្រាច់ ឃើញថា ព្រៃរក្សាទុកនៅក្នុងក្រុមហ៊ុនគឺត្រូវបានប្រជាជនចូលកាប់រាន ឬខាងណាក៏មិនដឹង តែជាក់ស្តែងព្រៃនោះត្រូវរុករានស្ទើរអស់ហើយដែរ ដូចនេះតើយើងគួលើកវិធានការយ៉ាងម៉េចចំពោះអ្វី ដែលនៅមានសេសសល់ទាំងនោះកុំឱ្យបន្តបាត់បង់បន្ថែមទៀត។

**បណ្ឌិត លី សុពណិ-មុនី :** ជាទូទៅគោលបំណងនៃការធ្វើកំណត់បង្ហាញនេះ គឺជាការផ្តល់យោបល់ដូចខ្ញុំបានលើកហើយគឺ វាឃើញថាមានផលប៉ះពាល់ ឧទាហរណ៍ថាព្រៃតំបន់ទ្រនាប់នេះដោយសារកិច្ចសន្យាទាំងអស់នេះជាភាសាខ្មែរ ឬក៏បានបកជាភាសាវៀតណាមហើយនូវ ហើយប្រហែលជាគាត់មិនទាន់បានយល់ពីកាតព្វកិច្ចរបស់គាត់ពីតំបន់ទ្រនាប់ បានធ្វើអោយមានការទន្ទ្រានពីមនុស្សខាងក្រៅ នៅក្នុងក្របខណ្ឌច្បាប់នៅក្នុងកិច្ចសន្យានេះ ជាបន្ទុករបស់ក្រុមហ៊ុន បើសិនជាឃើញថានេះជាចំណុចខ្វះខាតអញ្ចឹងយើងលើកដាក់ដូចបងខាង រដ្ឋបាលព្រៃឈើក៏បានលើកឡើងដែរថា តទៅយើងនិងមានវិធានការយ៉ាងម៉េចចំពោះបញ្ហានេះវាស្ថិតនៅក្រៅ សមត្ថកិច្ចរបស់ខ្ញុំនេះជាកុងស៊ុលតង់វះកាត់ថាត្រូវធ្វើម៉េច វាទាល់តែក្រុមជុំនាញ ហើយនិងអាជ្ញាធរ ខេត្តលើកឡើងអញ្ចឹងហើយពួកយើងនឹងសរសេរទៅនៅក្នុងរបាយការណ៍ ហើយពេលប្រជុំឆ្លងនៅក្រសួងបរិស្ថានរួចហើយចុងក្រោយនូវអន្តរក្រសួងគេលើកឡើងមក។ ពិសេសឯកឧត្តម **អ៊ិត ណូឌី** គាត់តែងតែចូលរួមប្រជុំនៅក្នុងការងារហ្នឹង មិនដឹងថាគាត់មានអនុសាសន៍យ៉ាងម៉េច នៅពេលដែលប្រជុំអន្តរក្រសួងតំរូវឱ្យដើរឡើងវិញ ឬមួយយ៉ាងម៉េច? យើងជ្រាបស្រាប់ហើយប្រព័ន្ធទឹកនៅតំបន់ក្រុមហ៊ុននេះ វាអាចហូរធ្លាក់ទៅមួយមករាកនិងហូរទៅស្ទឹងជីនិត ដូចនេះការសំរេចរបស់អន្តរក្រសួងថាគួរសំរេចរក្សាទុកព្រៃទ្រនាប់តាមដងអូរ នៅតំបន់នោះ ក្នុងចំងាយប៉ុន្មានម៉ែត្រពីមាត់អូរទាំងនោះទៅតាមអូរតូចៗឬក៏អូរធំៗ។

**ឯកឧត្តម អ៊ិត សំអន :** ពេលនេះខ្ញុំសូមមានយោបល់បន្ថែមទី១ភាគីក្រុមហ៊ុន ដែលមានកុងស៊ុលតង់នៅទីនេះ ដែលជាកត្តព្វកិច្ចរបស់ខ្លួនត្រូវបង្កើតផែនទីតំបន់ទ្រនាប់ផ្លូវទឹក មានអូរ ប្រឡាយ ស្ទឹង និងតំបន់ព្រៃរក្សា ទុកមានព្រៃស្រោង និងមតិណែនាំដល់ក្រុមហ៊ុនជៀសវាងទៅប៉ះពាល់តំបន់រក្សាទុកទាំងនោះ ដោយមិនធ្វើការឈូសឆាយ ដោយក្រុមហ៊ុនថែរក្សាឱ្យតំបន់នោះរក្សបាននូវស្ថានភាពដើម (ករណីក្រុមហ៊ុនឈូសលើស ហើយឈូសទៅចុះតែអ្វីដែលនៅសល់គឺរក្សាវាឱ្យនៅដដែល ជៀសវាងឈូសចូលថែមនិងកាប់រានបន្តទៀត) ករណីនេះក្រុមហ៊ុនអាចសួរមកវិញថា ធ្វើម៉េចខ្ញុំអាចរាំងខ្ទប់បាន? បើប្រជាពលរដ្ឋទៅកាប់សូម្បីតែអាជ្ញាធរគាត់មិនអាចរាំងខ្ទប់បានផងនោះ។ ដូចនេះការងារនេះ ទាមទារឱ្យយើងមានកិច្ចសហប្រតិបត្តិការគាល្អរវាងសមត្ថកិច្ច អាជ្ញាធរមូល និងក្រុមហ៊ុនចាប់ដៃគ្នាក្នុងការធ្វើការងារនេះទើបទទួលបានជោគជ័យ។ ឧទាហរណ៍ថា នៅតំបន់ **ភ្នំប្រាច់** គឺរងនូវការបំផ្លាញ ហើយដូចនេះ បើក្រុមហ៊ុនគាត់មិនអាចធ្វើការហាមឃាត់បានគាត់ត្រូវផ្តល់ពិតមាន ដើម្បីកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ ឬក៏អាជ្ញាធរមូលដ្ឋាន



Draft

ថា នៅកន្លែងនេះប្រជាជន ចេះតែចូលទៅរានព្រៃធ្វើការកាន់កាប់ដូចនេះ សុំឱ្យជួយមានវិធានការ ។ ចំណុចទី១ ទៀតបើតំបន់នោះវាមានការខូចខាតរួចទៅហើយ ដូចនេះតើយើងត្រូវធ្វើដូចម្តេចទៅវិញ ទី១ត្រូវស្គាល់ទីតាំងដែលយើងត្រូវទទួលខុសត្រូវឱ្យបានច្បាស់លាស់ ។ ទី២យើងត្រូវសិក្សាឡើង វិញថាតើព្រៃនោះទទួលរងការបំផ្លេចបំផ្លាញដូចម្តេច? ដោយកំណត់ឱ្យច្បាស់ថាចលករគឺជាអ្នកណា? បើប្រជាពលរដ្ឋយើងត្រូវសហការជាមួយអាជ្ញាធរ ទើបអាចដឹងថាប្រជាពលរដ្ឋទាំងនោះចេញមកពីណាដែលអាជ្ញាធរ មានសមត្ថកិច្ចត្រូវធ្វើការគៀងគរប្រជាពលរដ្ឋរបស់ខ្លួនទាំងនោះឱ្យត្រឡប់ទៅភូមិរបស់គាត់វិញ ។ ទី៣ក្នុងករណី យើងទទួលបានថាក្រុមហ៊ុនមិនបានអនុវត្តន៍ឱ្យបានត្រឹមត្រូវតាម (ស.ជ.ណ) របស់រាជរដ្ឋាភិបាល ឈូសឆាយប៉ះពាល់ដល់ព្រៃដែលបានរក្សាទុក ជាប្រយោជន៍នោះ អាជ្ញាធរត្រូវជូនដំណឹងជំរាបទៅរកក្រុមហ៊ុនឱ្យបញ្ឈប់ការឈូសចូលទៅមុខទៀត ដូចនេះយើងត្រូវសិក្សាថាតើត្រូវដាំឡើងវិញឬក៏យ៉ាងម៉េច? ដែលតំរូវឱ្យយើងចុះសិក្សាឡើវិញផងដែរ ។

**លោក សុទ្ធ ម៉ារី** នាយផ្នែករដ្ឋបាលព្រៃឈើកំពង់ធំ : សុំចូលរួមយោបល់បន្ថែមទៀតដែរអំពីការកាប់រាននៅតំបន់ព្រៃរក្សាទុក ហើយខាងខ្ញុំក៏ទទួលបាននៅការបញ្ជាផ្ទាល់តាមរយៈឯកឧត្តមរដ្ឋមន្ត្រីរបាយការណ៍ កាប់រានព្រៃនៅតំបន់ភ្នំប្រាច់នេះ ដែលរងនូវសកម្មភាពធ្ងន់ធ្ងរ ហើយខាងរដ្ឋបាលព្រៃយើងខ្ញុំនេះមិនមែនមិនមានការចាប់អារម្មណ៍ មិនអើពើរនោះទេ ដោយមានសំណើរពីក្រុមហ៊ុនមករដ្ឋបាលព្រៃឈើ យើងដែរ ក្នុងការសហការណ៍រកវិធានការដោះស្រាយ ហើយទិដ្ឋភាពការងារសព្វថ្ងៃនេះ ហាក់ដូចជាមិនទាន់មានការចូលរួមពេញលេញពីភាគីក្រុមហ៊ុននៅឡើយនោះទេ គឺថាការងារធ្វើដោយឡែក១ពីគ្នា ករណីនេះគឺចង់សំដៅទៅលើការចុះអនុវត្តន៍ការងារ ដែលស្តែងចេញពីបញ្ជាថវិកាតែម្តង ។ ក្នុងការចុះអនុវត្ត ការងារដែលកន្លងមកយើងទាមទារឱ្យខាងក្រុមហ៊ុនចូលរួម ដើម្បីមានលទ្ធភាពផ្តល់នូវអ្វីដែលជាសេវាគាំទ្រ (ថវិកា) ក្នុងការងាររួមសហការណ៍គ្នា ប៉ុន្តែលទ្ធផលនោះពេលយើងដាក់សំណើទៅឃើញថាមានផលវិជ្ជមានតិចតួចឆ្លៀតឱកាសថ្ងៃនេះ តាំងនាមឱ្យខ័ណ្ឌរដ្ឋបាលព្រៃឈើ សំណូមពរដល់ឯកឧត្តមប្រធានអង្គប្រជុំ ថាការងារនេះជាទូទៅត្រូវតែ បើកទំព័រការងារជាប្រវត្តិសាស្រ្តការងារមួយនៅលើក្រុមហ៊ុនទាំងបីនេះ ដូចខាងមន្ទីរកសិកម្មលើកឡើងហើយ ដើម្បីបានជាគំរូមួយទៅដល់ក្រុមហ៊ុនក្រោយ១ ដូចនេះយើងគួធ្វើការងារឱ្យមានលក្ខណៈលំអិតដោយឡែកលើកនូវអ្វីដែលកំពុងតែមានសកម្មភាព ដូចជាករណីដីដែលឈូសឆាយដាំកៅស៊ូរួចអស់ហើយ យើងគួរតែជំរុញបញ្ចេញរបាយការណ៍ទៅ ឱ្យថ្នាក់ដឹកនាំខាងលើបានជ្រាបបានហើយដើម្បីបញ្ចប់បញ្ហានេះ សូមអគុណ ។

**ឯកឧត្តម អ៊ិត សំអន** : តាមប្រសាសន៍របស់រដ្ឋបាលព្រៃឈើ និង មន្ទីរកសិកម្ម គឺសំណូមពរធ្វើយ៉ាងណា ឱ្យបានល្អដើម្បីជាបទពិសោធន៍ទៅដល់ក្រុមហ៊ុនដទៃ តែវាអាចប៉ះពាល់ខ្លះទៅនិងប្រសិទ្ធិភាព

Draft

អនុវត្តន៍របស់ក្រុមហ៊ុន មានន័យថាក្រុមហ៊ុនធ្វើបានលទ្ធផលមួយចំនួនល្អប្រសើរហើយតែមានចំណុចខ្លះមិនទាន់មានប្រសិទ្ធិភាពខ្ពស់។ ដូចនេះហើយទើបថ្ងៃនេះកុងស៊ុលតង់មកបង្ហាញឱ្យសមត្ថកិច្ចយើងថា ឥឡូវនេះក្រុមហ៊ុនធ្វើបានអញ្ចេះលើសផែនការប៉ុណ្ណេះខ្វះផែនការប៉ុណ្ណោះ សុំឱ្យសមត្ថកិច្ចជំនាញចូលរួមបំពេញបន្ថែមនៅចំណុចខ្វះ ខាតទាំងនោះដើម្បីឱ្យត្រឹមត្រូវនឹងបានល្អប្រសើរ ទៅតាមនូវអ្វីដែលក្រុមហ៊ុនរំពឹងគិត។

**បណ្ឌិត លី សុពិណ-មុនី :** ពាក់ព័ន្ធនឹងបញ្ហានឹងយើងត្រូវត្រួតពិនិត្យទៅលើផែនទី ដែលមាននៅក្នុងការមេ ឧទាហរណ៍ ក្រុមហ៊ុនមានផ្ទៃដីជាងប្រាំបួនពាន់ហិកតានឹង តើគាត់បែងចែកជាប្រមាណអនុតំបន់? ក្នុងនោះ ព្រៃរក្សាទុកមានប៉ុន្មាន ដែលព្រៃរក្សាទុកនោះត្រូវបានបែងចែកជា២ ជាប្រភេទព្រៃស្រោងដែលមានឈើពូជ នៅក្នុងនោះ ហើយជាប្រភេទឈើព្រៃដែលមានដុះនៅតាមតំបន់ទ្រនាប់ផ្លូវទឹក ដូចនេះយើងត្រូវមើលទៅ លើនោះដែរថាព្រៃរក្សាទុមមានប៉ុន្មាន? ហើយក្រុមហ៊ុនបានប៉ះពាល់ទៅលើព្រៃទាំងនោមានទំហំប៉ុន្មាន? អញ្ចឹងការងារ EIA បានត្រឹមតែសរសេរនៅក្នុងអនុសាស្តន៍ទេ នៅក្នុងការវិភាគស្តីពីការប៉ះពាល់យើងនឹងសរសេរនៅក្នុងឃ្លាមួយថា នៅក្នុងព្រៃរក្សាទុកមានចំនួនប៉ុណ្ណេះ ចុងក្រោយក្រុមហ៊ុនបានឈូសអស់ប៉ុណ្ណោ ទាល់តែចូលទៅប្រជុំនៅអន្តរក្រសួងទើបអាចសំរេចបាន។ ឧទាហរណ៍ នៅក្នុងផែនទីនេះអញ្ចឹងនៅតាមអូរតូចៗ បើនៅក្នុងផែនការមេកាត់កាត់ទុកតំបន់ទ្រនាប់ទាំងនោះចេញនោះបើក្រុមហ៊ុនឈូសអស់យើងអាចបន្ទោសគាត់បាន តែបើក្នុងផែនការមេគាត់មិនបានកាត់ យើងក៏ពិបាកនឹងបន្ទោសគាត់ដែរ។ ព្រោះយើងមិនមានវិធានការជាក់លាក់ណាមួយថា មិនថាអូរ ឬស្នាមទឹកហូរទេ យើងត្រូវទុក៥ម៉ែត្រឬ១០ម៉ែត្រសងខាងយើងចាំបាច់ត្រូវទុក តែបើក្រុមហ៊ុនឈូសនោះក្រុមហ៊ុនត្រូវទទួលខុសត្រូវ ជាក់ស្តែងចំពោះក្រុមហ៊ុនទាំងបីនេះនៅពេលដែលខ្ញុំត្រឡប់ទៅវិញ ខ្ញុំនឹងបើកផែនទីក្នុងផែនការមេមើលថា នៅក្នុងផ្ទៃដីចំនួនប្រាំពីរពាន់ហិកតាជាងនេះតើផ្ទៃដីដែលត្រូវរក្សាទុកនេះវាមានប៉ុន្មាន? ដូចនេះយើងត្រូវពិនិត្យមើលទៀតថា ដោយរបាយការណ៍នេះជារបាយការណ៍ដំបូង អញ្ចឹងខ្ញុំមិនអាចចូលទៅដល់ចំណុចព្រៃរក្សាទុកចំណុចនោះមានជាងមួយរយហិកតា នោះ តើវានៅសល់ទាំង១០០ហិកតា ឬប៉ុន្មានរយហិកតា ខ្ញុំមិនមានតួនាទីលំអិតអញ្ចឹងបានទេ ប៉ុន្តែប្រសិនបើមានរបាយការណ៍ជាក់លាក់ណាមួយថា ព្រៃដែលត្រូវរក្សាទុកទាំងអស់នោះត្រូវបានបំពាន ដូចនេះនៅក្នុងរបាយការណ៍ យើងសរសេរថាព្រៃរក្សាទុកមួយចំនួនត្រូវបានបំពាន ដែលអាចមាន២មូលហេតុ ទីមួយដោយសារប្រព័ន្ធមេការការដ្ឋាននោះគាត់មិនស៊ីជំរៅផ្នែកពិតមានភូមិសាស្ត្រនៅពេលដែលឈូសទៅគាត់ឈូសចូល ១០មែត្រឬ២០ម៉ែត្រ អីនឹង ហើយមួយទៀតប្រជាជនដែលរស់នៅក្បែរខាងនោះកាត់លួចចូលទៅស្ទាត់ៗលុងនៅកណ្តាលនោះប្រាំហិកតាឬដប់ហិកតា អីចឹងទៅដើម្បីដាំដំឡូង អញ្ចឹងយើងគ្រាន់តែបានដាក់កំណត់នៅក្នុង របាយការណ៍អញ្ចឹងដល់ពេលចុងក្រោយវាមានតែអង្គភាពពាក់ព័ន្ធដូចជាក្រសួងកសិកម្ម ក្រសួងបរិស្ថានរដ្ឋបាល ព្រៃឈើ ចុះពិនិត្យជាក់ស្តែងនឹងមានវិធានការយ៉ាងម៉េច? ដែលក្រុមហការងារយើងបាន

Draft

ត្រឹមតែសរសេរបាយការណ៍ទាំងនោះចូលទៅទេ ទាល់តែដាក់របាយការណ៍នេះចូលទៅប្រជុំអន្តរក្រសួងទើបមានវិធានការ ថាតើត្រូវធ្វើដូចម្តេច? សូមអគុណ។

**លោក ហុង សេងហាក់** មន្ត្រីការិយាល័យផែនការកសិកម្មខេត្ត ៖ នៅក្នុងរបាយការណ៍ដែលបានធ្វើបទ បង្ហាញនេះ ឃើញថាក្រុមហ៊ុនបានធ្វើការឈូសឆាយដាំដុះស្ទើរតែរួចអស់ទៅហើយ ប៉ុន្តែនៅក្នុងនេះយើងគិត ថាការវាយតំលៃហេតុប៉ះពាល់បរិស្ថានយើងគួតែរំលេចនៅចំណុចណាមួយដែលយើងបានបញ្ជាក់ថាមិនបានធ្វើ ការវាយតំលៃទៅលើសកម្មភាពជាក់ស្តែងរបស់ក្រុមហ៊ុនត្រង់ចំណុចនេះខ្ញុំចង់បញ្ជាក់ថាដោយក្នុងរបាយការណ៍ នេះសរសេរថាជារបាយការណ៍ដំបូង ដូចនេះចង់បានឱ្យក្រុមហ៊ុនកុងស៊ុលតង់សរសេរចងត្រង់ណាមួយ ដើម្បីឱ្យ ដឹងថារបាយការណ៍នេះនៅមានសល់ចំណុចនានាដែលយើងមិនទាន់បានធ្វើ ?

**បណ្ឌិត លី សុពិណា-មុនី** ៖ ជាទូទៅតំលាប់នៃការធ្វើ EIA មិនចាំបាច់ចងនូវអ្វីអញ្ចឹងនោះទេ ដែលខ្ញុំធ្លាប់ធ្វើមក១២ឆ្នាំហ្នឹង នៅពេលដែលយើងវាយផលប៉ះពាល់ដំបូង នៅក្នុងចំណុចមួយយើងនឹងសរសេរអំពីភាពចំបាច់នៃការវាយតំលៃប៉ះពាល់បន្ថែម ឧទាហរណ៍ក្រុមហ៊ុន ភឿក វ៉ា អញ្ចឹង នៅក្នុងឃ្លាមួយយើងសរសេរថាគំរោងអភិវឌ្ឍន៍កៅស៊ូរបស់ក្រុមហ៊ុន PHUOC HOA KAMPONGTHOM APHIVATH CAOUTCHOUC Co., Ltd. មានទីតាំងស្ថិតនៅក្នុងឃុំក្រយា និងឃុំបឹងល្វា ស្រុកសន្ទុក ក្រោយពីបានការអនុម័តអោយមានការអភិវឌ្ឍន៍ហើយក្រុមហ៊ុនត្រូវសហការណ៍ជាមួយក្រុមជំនាញ ដើម្បីធ្វើការវាយតម្លៃហេតុប៉ះពាល់អោយបានពេញលេញ។ ការវាយតម្លៃហេតុប៉ះពាល់បន្ថែមត្រូវយកចិត្តទុកដាក់ ទៅលើបញ្ហាមួយចំនួនដូចជា៖

ក- ភាពសម្បូរណ៍របស់សារព័ន្ធរុក្ខជាតិ និងសត្វនៅក្នុងតំបន់សម្បទាន អោយបានលំអិត។

ខ- ធ្វើសារពើភ័ណ្ឌអោយបានច្បាស់លាស់ ដើម្បីឈានទៅធ្វើការវាយតម្លៃអំពីបរិមាណ ជីវៈម៉ាស់ និងសន្និធិកាបូន និងការផ្លាស់ប្តូរនូវសន្និធិនេះ នៅក្នុងរយៈពេលនៃវដ្តផលិតកម្មកៅស៊ូ។

គ- កំណត់អត្តសញ្ញាណ និងទំហំផ្ទៃដីរបស់ប្រជាពលរដ្ឋមូលដ្ឋានដែលពាក់ព័ន្ធ អោយបានត្រឹមត្រូវ ដើម្បីធ្វើការដោះស្រាយអោយទាន់ពេលវេលា ជៀសវាងការមានទំនាស់កើតមានឡើង ដោយយថាហេតុ។ នេះយើងធម្មតារបាយការណ៍យើងធ្វើមួយហើយ យើងយកមួយទៀតមកកែរនេះមិនមែនសំរាប់ **ភឿក វ៉ា** នោះទេ ព្រោះ **ភឿក វ៉ា** នៅសល់តែ ៦០០ហិកតា ហើយ មិនដឹងថា សំរាប់ដាំឆ្នាំក្រោយនោះគាត់បានអញ្ជើញក្រុមការងារជំនាញទៅចុះទៅធ្វើសារពើរភ័ណ្ឌហើយ ឬនៅ ដល់ពេលកាលចុង២០០៩ ដើម២០១០ មានការណែនាំជាអនុសាសន៍របស់ បណ្ឌិតឯកឧត្តមទេសរដ្ឋមន្ត្រីក្រសួងបរិស្ថាន ឱ្យចុះធ្វើសារពើព័ន្ធទោះបីការងារនោះជារបស់ក្រសួងកសិកម្ម ឬសាមីក្រុមហ៊ុនក៏ដោយ ឧទាហរណ៍៖ ដូចជាក្រុមហ៊ុន **ហេង អភិវឌ្ឍន៍** និងក្រុមហ៊ុន **យូនីប្រ៊ីន** សុទ្ធតែធ្វើសារពើព័ន្ធ តែក្រោយមកក្នុងខែ៨ឆ្នាំ២០១០ វាមានចេញ សេចក្តីប្រកាស មួយទៀតធ្វើការ

កែតំរូវប្រកាសលេខ១២៧៦ អំពីការធ្វើសារពើភ័ណ្ឌ ស្តីពីការ បង់ព័ន្ធ អញ្ចឹងហើយនៅក្នុងការប្រជុំអន្តរក្រសួង ឆ្លងបានលើកឡើងថាមិនចាំបាច់ធ្វើសារពើភ័ណ្ឌទេ នៅក្នុងពេលកែតំរូវនោះល្អសិន ពីព្រោះអីរាជរដ្ឋាភិបាល បានអនុញ្ញាតអោយ ធ្វើការប្រែក្លាយដីនឹងទៅជាដីកសិ-ឧស្សាហកម្មរួចទៅហើយ អញ្ចឹងបានន័យ ថាឈើពាណិជ្ជកម្មនៅតំបន់នោះវាខុសពីឈើពាណិជ្ជកម្មនៅព្រៃគុប ឬមួយក៏យើងអាចថាព្រៃសម្បទានដែល យើងមានកន្លងមក អញ្ចឹងល្អសហើយចាំឱ្យក្រុមជំនាញចុះទៅពិនិត្យ បើល្អសហើយឈើនោះក្រុមហ៊ុនមានការ ចាប់អារម្មណ៍ ក្នុងការប្រើប្រាស់ឈើ គឺមានការគរទុកទៅ ចុងក្រោយក្រុមជំនាញចុះទៅធ្វើការវាយត្រាឈើនោះ ជាទូទៅឱ្យតែដំបូងថា ចងក៏ថាបានដែរ ប៉ុន្តែបើពួកខ្ញុំសរសេរជាប្រចាំអញ្ចឹង នៅក្នុងជំពូកទី៥ស្តីពីការកំណត់សក្តានុពលសេដ្ឋកិច្ចនោះយើងសរសេរអត់អស់ទេ អញ្ចឹងយើងអាចនិយាយថាចងក៏បានដែរ ប៉ុន្តែយើងប្រើពាក្យភាពចាំបាច់ នៃការវាយតំលៃហេតុប៉ះពាល់បន្ថែមរបស់ក្រុមហ៊ុន។

**លោក ហុង សេងហាក់** មន្ត្រីការិយាល័យផែនការកសិកម្មខេត្ត : ចំពោះមតិរបស់ឯកឧត្តម អស់លោកនិយាយខ្ញុំយល់ ប៉ុន្តែខ្ញុំចង់និយាយថាការដែលធ្វើយ៉ាងដូច្នេះ និយាយរួមរាល់ថ្ងៃខ្ញុំភ័យដោយសារការងារសព្វថ្ងៃខ្ញុំមានភារកិច្ចចូលរួមក្នុងការងារនោះដែរ អញ្ចឹងពាក់ព័ន្ធ និងក្រុមហ៊ុនល្អសខុសទីតាំង បើមិនមានដាំកៅស៊ូ ហើយប្រជាជនចូលកាប់រានវាអត់មានបញ្ហាទេ កៅស៊ូរបស់ក្រុមហ៊ុនជាប់ឡូតិ៍ទៅអញ្ចឹងខ្ញុំគិតថា គួរតែយើងមិនទាន់បានសិក្សានៅឡើយ ហើយលោកនាយកអំម្បាញ់មិញក៏ថាមិនបានចុះសិក្សា កំណត់បានថាក្រុមហ៊ុននោះល្អសលើសឬ ខ្វះចំណុចណាខ្វះនិយាមកាដែលបានកំណត់នៅក្នុងផែនការមេ ឬនិយាមកានៅក្នុងផែនការប្រើប្រាស់ដីរបស់ក្រុមហ៊ុននីមួយៗទេ នេះគ្រាន់ត្រជាការព្រួយបារម្ភទេ នៅអ្វីដែលខ្ញុំលើកពេលខ្លះគោលនយោបាយរបស់រាជរដ្ឋាភិបាលធ្វើសម្បទានដីនោះខ្ញុំដឹងហើយ ប៉ុន្តែពេលខ្លះ យើងគិតថាថ្នាក់ជាតិគាត់សំរេចគោលនយោបាយរបៀបម៉េចទេ ប៉ុន្តែគាត់ទំលាក់មកអាជ្ញាធរ ទំលាកមកថ្នាក់ស្រុក ខេត្ត ជំនាញរដ្ឋបាលព្រៃឈើ កសិកម្ម ឬ បរិស្ថាន ជាសេនាធិការជូនថ្នាក់ជាតិ ប៉ុន្តែអត់បានធ្វើចំណុចនេះហើយយើងក៏មិនបានរាយការណ៍ជូនទៅថ្នាក់លើ វិញថាចំណុចនោះវាយ៉ាងចេះៗ យើងមិនបានរាយការណ៍វាជាការខ្វះចនោះរបស់ថ្នាក់ក្រោម។

**ឯកឧត្តម អ៊ុត សំអន អភិបាលរងខេត្ត កំពង់ធំ** : នៅក្នុងរបាយការ ធ្វើបទបង្ហាញនៅថ្ងៃនេះ ឃើញថាមាន ក្រុមហ៊ុនមួយមានលិខិតផ្ទេរហើយ តែក្រុមហ៊ុនមួយទៀតមិនទាន់មានលិខិតផ្ទេរនាមករណ៍ក្រុមហ៊ុនជាផ្លូវការនៅឡើយទេ។ ដែលក្នុងការអនុត្តន៏របស់ក្រុមហ៊ុនទាំងនេះគឺមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន រីឯចំណុចវិជ្ជមានទាំងរាជរដ្ឋាភិបាល ទាំងយើងផ្ទាល់ទទួលស្គាល់ថាក្រុមហ៊ុនទាំង៣នេះ ពិតជាមានសមត្ថភាពក្នុងការអនុវត្តពិតប្រាកដមែនតួយ៉ាងដូចជានៅខេត្តកំពង់ធំយើងនេះ មានក្រុមហ៊ុនប្រមានជា២០ មកយូរឆ្នាំហើយក្តីខ្លះមក មុនក្រុមហ៊ុនវៀតណាម ខ្លះមកស្មើគ្នា យើងឃើញថាមិនមានក្រុមហ៊ុនមួយបានបង្កភាពលេចធ្លោ ដូចក្រុមហ៊ុន វៀតណាមនេះទេ។ ឃើញតែមានរការកូស ឃើញតែទទួលបាន (**សជណ**) គឺធ្វើទុក

Draft

សំរាប់រកដៃគូរ ហើយក្រុមហ៊ុនខ្លះមិនរកដៃគូរទេ តែធ្វើសំរាប់ចិញ្ចឹមញូចលនានៅនឹងកន្លែង ឬអាចនិយាយថាយកសកម្មភាពនៅកន្លែងចិញ្ចឹមឱ្យសកម្មភាពវិនិយោគផ្ទាល់ បានន័យថាដាំដិឡូងទៅលក់បានផលហើយពង្រីកដាំបន្តិចៗ ឬមួយទៀតធ្វើផងរង់ចាំការលក់យកចំណេញតែម្តង។ ដូចនេះយើងឃើញថាក្រុមហ៊ុននេះមានការជាក់លាក់ណាស់មិនទាន់អីផងគាត់ដាក់គ្រឿងចក្រសំរាប់សាងសំណង់ហេដ្ឋារចនាសម្ព័ន្ធ ទាំងឡាយព្រោងព្រាតហើយសកម្មភាព វិជ្ជមានមួយទៀតគឺការជួយដោះស្រាយ ក្នុងការផលប៉ះពាល់សង្គម គឺថាក្រុមហ៊ុនវៀតណាមធ្វើការដោះស្រាយបានល្អដោយសារតែក្រុមហ៊ុននេះយល់សភាពការនៅកម្ពុជា ហើយក្រុមហ៊ុននេះ គឺធ្វើកិច្ចសហប្រតិបត្តិការល្អជាមួយនឹងអាជ្ញាធរមូលដ្ឋាន និយាយឱ្យខ្លីទៅក្រុមហ៊ុននេះចាយលុយដើម្បីជោគច័យសំរាប់ការងារ។ ហើយកិច្ចប្រជុំថ្ងៃនេះ ក៏ធ្វើឱ្យយើងទទួលបានជោគជ័យជាមួយក្រុមហ៊ុនដែរ ដូចជាការដោះស្រាយកោលនយោបាយជាមួយប្រជាពលរដ្ឋ គ្រប់ទីកន្លែងគឺប្រជាពលរដ្ឋទទួលយកបានទោះជាមានបញ្ហាខ្លះវាអាចទៅមុខទាំងអស់គ្នាហើយ ហើយទទួលបានការជោគជ័យលើការដាំដុះនោះលើសគំរោង គឺឆ្នាំ២០០៧ និង២០១០ ។ នេះវាជាជោគជ័យរបស់ក្រុមហ៊ុន ហើយក៏ជាជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា វាក៏ជាជោគជ័យរបស់ខេត្តកំពង់ធំ ដែលយើង ថាលទ្ធភាពនៃការស្រូបយកនូវកំលាំងការងារនៅក្នុងតំបន់ ទៅបីប្រជាជននៅក្បែនោះមិនទាន់យល់អំពីលទ្ធផលនៃការងារនៅពេលគេយកពូកគាត់និងយល់។ នៅពេលអនាគតឥទ្ធិពលនៃការងារពលកម្មនេះនឹងមានទៅដល់ប្រជាពលរដ្ឋទាំងនោះដោយបំលែងពីកសិករទៅជាកម្មករ ឬពលករនៅក្នុងក្រុមហ៊ុនវិញជាងនេះទៅទៀត នៅពេលមានការលូតលាស់ និងមានរោងចក្រហើយការងារចេះតែមានច្រើនទៅទៀតទោះបីជាមានចំណុចអវិជ្ជមាន ឬ បញ្ហាខ្លះមួយចំនួនកើតឡើងក៏ដោយ ក៏ប៉ុន្តែយើងត្រូវទទួលស្គាល់ថាក្រុមហ៊ុនទទួលបានជោគជ័យ ហើយលទ្ធផលនេះយើងទទួលយកការចែករំលែកតាមរយៈនៃកការអនុវត្តន៏ច្បាប់ក្នុងស្រុកឬក៏យើងមានកំណើនការងារហើយក៏យើងនឹងរៀបចំការក្នុងការងារសង្គម នូវអ្វីដែលជាចំណុចអវិជ្ជមាននោះយើងមិនព្រងើយកន្តើយទេ នៅក្នុងការពិគ្រោះយោប់នេអយើងផ្តោតនៅកំណត់ហេតុដើម្បីយកទៅប្រើប្រាស់នៅថ្នាក់ជាតិ បើសិនជាការពិភាក្សានេះផ្តល់យោបល់ថា តើអ្នកណាត្រូវធ្វើអ្វីនោះដាក់វិធានការអ្វី យើងត្រូវរង់ចាំការមានវិធានការតទៀត ដើម្បីធ្វើយ៉ាងណាឱ្យមានការទទួលខុសត្រូវឱ្យមានប្រសិទ្ធិភាពកាន់តែខ្ពស់ តែមិនផ្តល់ឱ្យនរណាម្នាក់ ឬ ប្រជាជនចូលទៅរុករាបប៉ះពាល់នៅព្រៃដែលក្រុមហ៊ុនមានកត្វកិច្ចការពារនឹងថែរក្សាទុកឱ្យបានគង់វង្សនោះទេ។ ទី២គ្រប់សមត្ថកិច្ចត្រូវមានការសហការជាមួយក្រុមហ៊ុនឱ្យបានល្អជាប្រចាំ ក្នុងករណីក្រុមហ៊ុនបានផ្តល់ពិតមានស្តីពីការចូលកាប់រានកាន់កាប់ពីសំណាក់ប្រជាជនឬពីខាងណានោះ ដែលមានរដ្ឋបាលព្រៃឈើ កសិកម្ម និងអាជ្ញាធរនៅមូលដ្ឋានផ្តល់នោះឯងតែម្តង ហើយចំពោះអាជ្ញធរដែនដីមានមធ្យោបាយ២គឺទី១អប់រំអូសទាញប្រជាពលរដ្ឋខ្លួនឱ្យអនុវត្តច្បាប់ ឱ្យយល់ដែលអាចកាត់បន្ថយបាននូវបទល្មើស ទី២សហការជាមួយកងកំលាំងប្រដាប់អាវុធក្នុងការចូលរួមទប់ស្កាត់បង្រ្កាបបទល្មើសជាក់ស្តែង។ សរុបមកក្នុងនាមអង្គប្រជុំទាំងមូលយល់ស្របចំពោះ របាយការវាយតំលៃក្នុងការចុះអង្កេតនេះ។ ហើយក្នុងនាមសមត្ថកិច្ចដែលចូលរួមប្រជុំនៅ

Draft

ពេលនេះត្រូវចាត់ទុកថា ការងារនេះមិនមែនជាការងារដោយឡែកនោះទេ ត្រូវតែមានការចូលរួមទទួលខុសត្រូវការងារនោះដើម្បីគាំទ្រដល់គំរោងអភិវឌ្ឍន៍វិនិយោគដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ឱ្យមានភាពរីកចំរើនទៅមុខជាលំដាប់។

សរុបសេចក្តីមក (១)ក្រុមហ៊ុនត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជំនាញពាក់ព័ន្ធដើម្បីដោះស្រាយរួមគ្នា ដោះស្រាយឱ្យអស់នូវហេតុផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ បើមានត្រូវដោះស្រាយឱ្យអស់។ (២) រួមគ្នាដោះស្រាយបញ្ហាបរិស្ថានបញ្ចៀសការ ឈូសឆាយ អូរ បឹង ស្ទឹងបើមាន ដើម្បីថែរក្សាធនធានធម្មជាតិតាមដងអូរ និងការពារការហូរច្រោះដីដែលបណ្តាលពីការឈូសឆាយរបស់ក្រុមហ៊ុន ព្រោះបើគ្មានការទប់ស្កាត់ទេ អាចបណ្តាលឱ្យមានផលវិបាកទៅថ្ងៃណាមួយដែលយើងមិនអាចស្មានដល់។ (៣)ចំពោះដីព្រៃរកសាទុកដែលមាននៅក្នុងពេលបច្ចុប្បន្ន ទាំងក្រុមហ៊ុនទាំងអាជ្ញាធរត្រូវចូលរួមថែរក្សាមិនឱ្យមានការបាត់បង់បន្តទៅទៀតហើយ ចំពោះផ្ទៃដីព្រៃរក្សាទុកដែលក្រុមហ៊ុនឈូសចូល ឬដីព្រៃដែលប្រជាជនចូលកាប់រាននោះត្រូវរង់ចាំអនុសាសន៍របស់ថ្នាក់ដឹកនាំចេញសេចក្តីណែនាំដល់ក្រុមហ៊ុនថា តើគួរធ្វើយ៉ាងដូចម្តេច គួរឱ្យក្រុមហ៊ុនដាំស្តារព្រៃឡើងវិញ ឬយ៉ាងណា? (៤) អាជ្ញធរមូលដ្ឋានត្រូវធ្វើការណែនាំដល់ប្រជាជនមូលដ្ឋានរបស់ខ្លួន ឱ្យគាត់យល់អំពីច្បាប់ និងអំពីតំលៃតំបន់ព្រៃរក្សាទុកទាំងនោះ ហើយធ្វើការគៀងគរពួកគាត់មកវិញ បើមានចូលទៅរស់នៅតំបន់រក្សាទុកទាំងនោះ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១១:១៥ នាទីព្រឹកនៅថ្ងៃ ខែ ឆ្នាំ ដដែលក្រោមបរិយាកាសរីករាយស្និទ្ធស្នាល និងយោគយល់គ្នាខ្ពស់។

ធ្វើនៅកំពង់ធំ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១១

អ្នកធ្វើរបាយការណ៍

ហត្ថលេខា

Draft

Draft

Draft